**Declassified to Public**
**12 June 2020**

លេខ៖ D189/2

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 20 / 09 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**
កាលបរិច្ឆេទ ៖ **ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦**
ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]**
ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣ របស់ អោ អាន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដី អោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្ដី យឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01328405



## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤ មេធាវីការពារក្តីអោ អាន("មេធាវីការពារក្តី")បានដាក់ *សំណើលើកទីបីរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៥៥(១០)*[1]។

៣. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានបដិសេធសំណើនេះ ដោយកត់សម្គាល់ថា អោ អាន មិនទាន់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ ហេតុនេះមិនមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរឡើយ[2]។

៤. នៅថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានជូនដំណឹង អោ អាន អំពីដីកាសម្រេចដាក់គាត់ឲ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទួលបេង ទីតាំងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខវត្តអូរត្រកួន[3]។

៥. នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ មេធាវីការពារក្តី បានដាក់*សេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣* ("សំណើ")[4]។

៦. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មថែមទៀតនៅការដ្ឋានពលកម្មដោយបង្ខំអន្លង់ជ្រៃ មន្ទីរសន្តិសុខមិត្តសុប (គរ) វត្តអង្គញ្ជី មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយ

---

[1]សំណុំរឿង004 ឯកសារ D189 *សំណើលើកទីបីរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៥៥(១០)* ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤។

[2]សំណុំរឿង004 ឯកសារ D190 *ដីកាសម្រេចលើសំណើរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤។

[3]សំណុំរឿង004 ឯកសារ D242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[4]សំណុំរឿង004 ឯកសារ D189/1 *សេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ ("សំណើ")។

ចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក និងមន្ទីរសន្តិសុខវត្តស្រង៉ែ។ ខ្ញុំក៏បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ និងពីបទអំពើប្រល័យពូជសាសន៍មកលើជនជាតិចាមនៅខេត្តកំពង់ចាម។ ខ្ញុំបានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យដោយសារតំណែងពីមុនគាត់ជាអនុលេខាភូមិភាគកណ្តាល (ឧត្តរចាស់) ជាសមាជិកនៃគណៈភូមិភាគកណ្តាល(ឧត្តរចាស់) និងជាលេខាតំបន់ ៤១ នៅភូមិភាគកណ្តាល(ឧត្តរចាស់)[5]។

## II. សារណា

៧. សំណើរបស់មេធាវីការពារក្តី អាចចែកជាសំណើតូចៗចំនួនបួន ដែលខ្ញុំនឹងធ្វើការសង្ខេបដូចខាងក្រោម។

៨. ទី ១ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរបំពេញកិច្ចស៊ើបសួរឲ្យបានពេញលេញលើវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រភពផ្សេងទៀត បានប្រើប្រាស់ដើម្បី៖

ក) ធ្វើផែនទី និងជីករណ្តៅសាកសពរួមដែលបានចោទនៅទីតាំងវត្តអូរត្រកួន វត្តភ្នំប្រុស វត្តអង្គញជី គោកព្រីង និងទួលបេង។

ខ) គាស់យកអដ្ឋិធាតុជនរងគ្រោះនៅក្នុងរណ្តៅទាំងនោះ។

គ) កំណត់កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះ។

៩. ទី ២ មេធាវីការពារក្តី ស្នើសុំឲ្យស៊ើបសួរលើការដែលអាចមានភាពពុំត្រឹមត្រូវ និងវិធីសាស្ត្រខុសឆ្គងដែលបានប្រើប្រាស់ដើម្បីធ្វើការកំណត់ផ្សេងៗអំពីរណ្តៅសាកសពរួម និងស្នើសុំឲ្យវាយតម្លៃភាពអាចជឿជាក់បាននៃវិធីសាស្ត្រទាំងនោះ[6]។

---

[5]សំណុំរឿង០០៤ ឯកសារ D303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦។

[6]សំណើ កថាខណ្ឌ ២៨។

01328407



១០. ទី ៣ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដូចជាលោក ផេង វ៉ាស៊ី ទាក់ទងនឹងបញ្ហាប្រឈមនៅក្នុងការរៀបចំផែនទីរណ្តៅសាកសពរួមដែលបានចោទនៅភូមិភាគកណ្តាល[7]។

១១. ទី ៤ ដើម្បីជួយការស៊ើបអង្កេតខាងលើ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរតែងតាំងអ្នកជំនាញថ្មីខុសពីអ្នកជំនាញដែលបានតែងតាំងនៅក្នុងសំណុំរឿង ០០២[8]។

១២. មេធាវីការពារក្តី អះអាងថា ការចោទប្រកាន់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មខាងលើ មានភស្តុតាងបញ្ជាក់ជាបឋមតាមរយៈព័ត៌មានពីគម្រោងរៀបចំផែនទីរណ្តៅសាកសពរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[9] ហើយការរៀបចំផែនទីនេះភាគច្រើនធ្វើឡើងដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនមែនជាអ្នកជំនាញកោសលវិច័យដែលទទួលបានការបណ្តុះបណ្តាលឡើយ[10]។ បញ្ហាមួយក្នុងចំណោមបញ្ហាដែលមេធាវីការពារក្តី បានលើកឡើងទាក់ទងនឹងរណ្តៅសាកសមរួមទាំងនេះ គឺថាមិនអាចបែងចែកឲ្យខុសគ្នាបានរវាងការស្លាប់បណ្តាលមកពីអំពើរបស់ខ្មែរក្រហម ជាមួយនឹងការស្លាប់បណ្តាលមកពីមូលហេតុផ្សេងទៀត[11]។

១៣. បើតាមមេធាវីការពារក្តី បញ្ហាពាក់ព័ន្ធមួយទៀតគឺថា រណ្តៅសាកសពរួមទាំងនោះធ្លាប់ទទួលរងការប៉ះពាល់រួចហើយ ឧទាហរណ៍ ដោយសារអ្នកភូមិដែលរដ្ឋាភិបាលសាធារណៈរដ្ឋកម្ពុជាបានជំរុញឲ្យប្រមូលភស្តុតាងប្រឆាំងប៉ុល ពត[12]។ រណ្តៅសាកសពរួមក៏បានគាស់នៅចំហ និងត្រូវបានបំផ្លាញ ហើយឆ្អឹងសាកសពភាគច្រើនបានយកទៅទីកន្លែងគោរពវិញ្ញាណក្ខន្ធ[13]។

១៤. មេធាវីការពារក្តី ទទួលស្គាល់ថា របាយការណ៍អ្នកជំនាញប្រជាសាស្ត្រដែលបានរៀបចំឡើងសម្រាប់សំណុំរឿង ០០២ បានផ្តល់នូវទិដ្ឋភាពទូទៅអំពីវិធីសាស្ត្ររៀបចំផែនទីរណ្តៅសាក

---

[7]សំណើ កថាខណ្ឌ ២៩។

[8]សំណើ កថាខណ្ឌ ២៩។

[9]សំណើ កថាខណ្ឌ ៦។

[10]សំណើ កថាខណ្ឌ ៨។

[11]សំណើ កថាខណ្ឌ ១៤។

[12]សំណើ កថាខណ្ឌ ៧។

[13]សំណើ កថាខណ្ឌ ១០។

01328408



សព្វរូមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែ មេធាវីការពារក្តី អះអាងថា របាយការណ៍នេះ មិនបានវាយតម្លៃវិធីសាស្ត្រដែលបានប្រើប្រាស់សម្រាប់ទីតាំងឧក្រិដ្ឋកម្មជាក់លាក់នៅក្នុង សំណុំរឿង ០០៤ ឡើយ[14]។ មេធាវីការពារក្តី បន្ថែមទៀតថា របាយការណ៍អ្នកជំនាញ ប្រជាសាស្ត្រ មានការប៉ះពាល់ដោយសារមានភស្តុតាងដែលបានបង្ហាញនៅក្នុងដំណាក់កាល ជំនុំជម្រះក្តីសំណុំរឿង ០០២/០១[15]។

## III. ពិភាក្សា

១៥. អង្គបុរេជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ "ត្រូវបំពេញលក្ខខណ្ឌត្រួតលើគ្នាចំនួនពីរ [...] ពោលគឺ សំណើសុំត្រូវតែ៖

> (១) *កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់("លក្ខខណ្ឌនៃភាពច្បាស់លាស់")*
>
> (២) *បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ឬកិច្ចដែលកើតចេញមកពីដីកាដែលធ្វើឡើង អនុលោមតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង មានការ "ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត" ជាបឋម(លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម)*"[16]។

១៦. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឱ្យភាគីដែលស្នើ ជាប់កាតព្វកិច្ច "*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[17]។ ហេតុនេះ ខ្ញុំមិនជាប់លក្ខខណ្ឌត្រូវអនុញ្ញាតតាមសំណើមានលក្ខណៈជាទូទៅ ឬប៉ាន់ស្មាន ដែលស្នើសុំស្វែងរកភស្តុតាង

---

[14]សំណើ កថាខណ្ឌ ១១។

[15]សំណើ កថាខណ្ឌ ១១។

[16]សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ("សាលដីកាស្តីពីការពិចារណាឡើងវិញ") ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។

[17]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

ដោះបន្ទុកឡើយ[18]។ ប៉ុន្តែ ភាគីដែលស្នើ ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីវត្តមាននៃភស្តុតាងដែលត្រូវស្វែងរក[19]។ ឧទាហរណ៍ អ.ប.ជ បានសម្រេចថា សំណើសុំដែលមិនបានលើកឡើងច្បាស់លាស់អំពីចំនួនឯកសារ ឬអំពីទីតាំងច្បាស់លាស់ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់ឡើយ[20]។

១៧. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ មានលក្ខខណ្ឌរងចំនួនពីរ។ ទី ១ សំណើ ត្រូវ“*មានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*”[21]។ ទី ២ សំណើ “*ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាកិច្ចស្នើដែលជាកម្មវត្ថុនៃដីកាសម្រេចនឹងនាំឱ្យរកឃើញនូវការពិត*”[22]។ លក្ខខណ្ឌនេះតម្រូវថា ភាគីដែលស្នើសុំ ត្រូវបញ្ជាក់ពីចំណងទាក់ទងជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើសុំ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[23]។ ក្នុងករណីដែលសំណើពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក ភាគីដែលស្នើសុំ

---

[18]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨ និង ៥១។

[19]សំណុំរឿង០០២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។ សំណុំរឿង០០២ ឯកសារD164/4/13*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៨ និង ៧៣។ សំណុំរឿង០០២ ឯកសារ D164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៤៣។

[20]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[21]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៩។

[22]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០។

[23]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០-៥១។

ត្រូវបង្ហាញពីមូលហេតុជាបឋមដែលថា ការបំពេញកិច្ចស៊ើបសួរអាចនាំឱ្យមានភស្តុតាងដោះបន្ទុក[24]។

## ក. វិធីសាស្ត្រដែលប្រើប្រាស់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

*i.ការរៀបចំផែនទី*

១៨. ចាប់តាំងពីមេធាវីការពារក្ដីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្ដាប់ចម្លើយ ស៊ុន ឃិន និង ហាក់ សុផល ដែលអ្នកទាំងពីរនេះធ្លាប់ធ្វើការឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានចូលរួមរៀបចំរបាយការណ៍ស្ដីពីការរៀបចំផែនទីដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣[25]។ នៅខែ មករា ឆ្នាំ២០១៦ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក៏បានស្ដាប់ចម្លើយ ផេង ពង្សរ៉ាស៊ី[26]។ សាក្សីនីមួយៗក្នុងចំណោមសាក្សីទាំងនេះបានរៀបរាប់លម្អិតអំពីវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងការរៀបចំផែនទីរណ្ដៅសាកសពរួមនៅទូទាំងភូមិភាគពាយ័ព្យ[27]។

១៩. បន្ទាប់ពីបានត្រួតពិនិត្យមើលកំណត់ហេតុស្ដាប់ចម្លើយទាំងនេះ ខ្ញុំយល់ឃើញថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគកណ្ដាល គឺដូចគ្នានឹងវិធីសាស្ត្រដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នានាដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣។ ហេតុនេះ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែម

---

[24] សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។

[25] សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D219/363 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាក់ សុផល* ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥។

[26] សំណុំរឿង០០៤ ឯកសារ D219/144 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផេង ពង្សរ៉ាស៊ី* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥។

[27] សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ. ១-ឆ. ១៩។ សំណុំរឿង០០៤ ឯកសារ D219/363 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាក់ សុផល* ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D219/144 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផេង ពង្សរ៉ាស៊ី* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥។

ទៀតលើវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់នៅក្នុងការរៀបចំផែនទីទីតាំងរណ្ដៅសាកសពនៅវត្តអូរត្រកួន វត្តអង្គញដី គោកព្រីង និងទួលបេង ឡើយ។

២០. ដូចដែលខ្ញុំធ្លាប់បានបញ្ជាក់រួចហើយ[28] នៅក្នុងការគណនាចំនួនជនរងគ្រោះដែល អោ អាន អាចទទួលខុសត្រូវ ខ្ញុំនឹងពឹងផ្អែកជាចម្បងលើសាក្សីដែលអាចផ្ដល់ភស្តុតាងផ្ទាល់អំពីទីតាំងឧក្រិដ្ឋកម្មទាំងនោះ។ នៅក្នុងដីកាដំណោះស្រាយ ខ្ញុំនឹងពឹងផ្អែកតែលើឯកសារណាដែលជាមូលដ្ឋានសម្រាប់ការប៉ាន់ស្មានរបស់ ស.ព.អ តែត្រឹមចំណុចណាដែលខ្ញុំយល់ឃើញថាឯកសារទាំងនោះអាចជឿជាក់បាននៅក្នុងបរិបទនៃការស៊ើបសួរទាំងមូលតែប៉ុណ្ណោះ។

២១. ហេតុនេះ ការស៊ើបអង្កេតថែមទៀតទាក់ទងនឹងវិធីសាស្ត្រដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនចាំបាច់ធ្វើឡើងឡើយ ហើយនឹងមិនជួយការពារក្ដី អោ អាន ផងដែរ។

*ii. ការជីកគាស់យកអដ្ឋិធាតុ*

២២. មេធាវីការពារក្ដី ស្នើថា ខ្ញុំគួរស៊ើបអង្កេតវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងការជីកគាស់យកអដ្ឋិធាតុរណ្ដៅសាកសពរួមចំនួន ៥ កន្លែងនៅភូមិភាគកណ្ដាល។ ដោយបានពិនិត្យមើលកំណត់ហេតុស្ដាប់ចម្លើយ ស៊ិន ឃិន[29] និង ហាក់ សុផល[30] ព្រមទាំងរបាយការណ៍អ្នកជំនាញប្រជាសាស្ត្រ[31] ទើបខ្ញុំជឿជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា មិនបានជីក ឬគាស់យកអដ្ឋិធាតុរណ្ដៅសាកសពរួមនៅទីតាំងណាមួយក្នុងចំណោម

---

[28]សំណុំរឿង004 ឯកសារ D188/1/1 *ដីកាសម្រេចលើសេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន* ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ៤៨ ។

[29]សំណុំរឿង004 ឯកសារ D219/366 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ. ១៤-ឆ. ១៥។

[30]សំណុំរឿង004 ឯកសារ D219/363 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាក់ សុផល* ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.៤។

[31]សំណុំរឿង ០០២ ឯកសារ D6.1.197 *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ("របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ")* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ERN00499441-00499442។

ទីតាំងឧក្រិដ្ឋកម្មទាំង ៥ ដែលបានបង្ហាញនៅក្នុងសំណើឡើយ។ ហេតុនេះ មិនចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតលើផ្នែកនេះនៅក្នុងសំណើឡើយ។

*iii. កំណត់កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះ*

២៣. អ្នកស៊ើបអង្កេតម្នាក់របស់ ក.ស.ច.ស បានស៊ើបអង្កេតបញ្ហានេះនៅក្នុងអំឡុងពេលស្តាប់ចម្លើយ ស៊ិន ឃិន។ អ្នកស៊ើបអង្កេតរូបនេះបានសួរគាត់យ៉ាងច្បាស់លាស់អំពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់អំពីមូលហេតុ និងពេលវេលានៃការស្លាប់របស់ជនរងគ្រោះនៅរណ្តៅសាកសពរួមទាំងនោះ[32]។ ស៊ិន ឃិន បានផ្តល់ភស្តុតាងដូចខាងក្រោម៖

> យោងតាមសាក្សីដែលពួកយើងបាននិយាយជាមួយ រាល់រណ្តៅទាំងនោះកប់អ្នកដែលត្រូវគេសម្លាប់ប៉ុណ្ណោះ។ ចំណែក អ្នកស្លាប់ដោយសារជំងឺ គេកប់នៅក្បែរមន្ទីរពេទ្យ។ យើងពុំបានសួរអំពីអ្នកស្លាប់ ដោយចាស់ជរាទេ ប៉ុន្តែ ភាគច្រើន អ្នកដែលមិនអាចធ្វើការបាន នឹងត្រូវគេយកទៅសម្លាប់ ព្រោះគេមិនទុកឱ្យស្លាប់តាមធម្មជាតិទេ[33]។

២៤. ស៊ិន ឃិន ក៏ត្រូវបានចោទសួរអំពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់អំពី "ឆ្នាំនៃការសម្លាប់ជនរងគ្រោះនៅក្នុងរណ្តៅណាមួយ"៖

> រណ្តៅមានច្រើនប្រភេទខុសគ្នា រណ្តៅខ្លះយូរខ្លាំងមកហើយៗបានរលុបបាត់ ចំពោះរណ្តៅបែបនេះ យើងបានព័ត៌មានអំពីទីតាំងរបស់វាពីប្រជាជនមូលដ្ឋាន។ រណ្តៅមួយចំនួនទៀតត្រូវបានគ្របដោយស្លឹកឈើតែប៉ុណ្ណោះ។ កន្លែងខ្លះ អាចប្រើអាប៊ុលឈូសដើម្បីជីករណ្តៅសម្រាប់ការសម្លាប់ចំនួនច្រើន។ រណ្តៅខ្លះនៅថ្មីៗនៅឡើយ ដូចនេះ សាក្សីអាចមើលឃើញរណ្តៅបើកចំហដែលមានសពទើបស្លាប់ថ្មីៗ[34]។
>
> [...]

[32]សំណុំរឿង00៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ. ៨ ឆ. ១១ និង ឆ. ១៧។

[33]សំណុំរឿង00៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.១៧។

[34]សំណុំរឿង00៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.៩។

តាមធម្មតា ពេលដែលខ្ញុំសម្ភាស ខ្ញុំតែងកត់ត្រាឆ្នាំនៃការសម្លាប់។ ប្រសិនបើសាក្សីបាននិយាយ ខ្ញុំប្រាកដជាកត់ត្រាឆ្នាំនោះទុកនៅក្នុងកូនសៀវភៅរបស់ខ្ញុំ។ ប៉ុន្តែ មានអ្នកសម្ភាសផ្សេងទៀត ដូចជា ផេង ពង្សរ៉ាស៊ី និង ហាក់ សុផល ជាដើម ក៏បានសម្ភាសសាក្សីដែរ។ ពេលខ្ញុំសរសេររបាយការណ៍របស់ខ្ញុំ ប្រសិនបើខ្ញុំមានព័ត៌មានអំពីឆ្នាំនៃការសម្លាប់ ខ្ញុំប្រាកដជាដាក់បញ្ចូលនៅក្នុងរបាយការណ៍[35]។

២៥. ខ្ញុំយល់ឃើញថា ការពន្យល់របស់ ស៊ិន ឃិន គឺគ្រប់គ្រាន់អាចយល់ពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះ។ ខ្ញុំបានបង្ហាញខាងលើរួចហើយថា ខ្ញុំនឹងពឹងផ្អែកជាចម្បងលើសាក្សីនៅក្នុងការគណនាចំនួនមនុស្សស្លាប់ដោយសារឧក្រិដ្ឋកម្មដែលសហព្រះរាជអាជ្ញាបានចោទ ហេតុនេះ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវពង្រីកធនធានថែមទៀតដើម្បីស៊ើបអង្កេតលើវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់នៅក្នុងការកំណត់អំពីមូលហេតុ និងពេលវេលានៃការស្លាប់របស់ជនរងគ្រោះឡើយ។

## ខ. វិធីសាស្ត្រដែលប្រើប្រាស់ដោយ"ប្រភពផ្សេងទៀត"

២៦. សំណើរបស់មេធាវីការពារក្តី ដែលស្នើថា ខ្ញុំគួរស៊ើបអង្កេតលើវិធីសាស្ត្រដែលប្រើប្រាស់ដោយ"*ប្រភេទផ្សេងទៀត*" គឺជាសំណើឥតមានប្រយោជន៍។ ដើម្បីឱ្យសំណើសុំបំពេញកិច្ចស៊ើបសួរមានសុពលភាព ជាដំបូង សំណើនេះត្រូវបង្ហាញពីភស្តុតាងជាក់លាក់ដែលត្រូវស្វែងរក[36]។ ដូចដែល អ.ប.ជ បានកត់សម្គាល់ ខ្ញុំ"*គ្មានកាតព្វកិច្ចអ្វីក្នុងការ"ស្វែងរកព័ត៌មានដែលមិនដឹងថាមានឬអត់"*ទេ ពីព្រោះថា សំណើសុំដែលមិនច្បាស់លាស់[...]*អាចមានការពន្យារ*

---

[35]សំណុំរឿង០០៤ ឯកសារD219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.១១។

[36]សំណុំរឿង ០០២ ឯកសារ D164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤៣។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១៩។ សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៧៤។

*ពេលកិច្ចដំណើរការនីតិវិធីហួសហេតុ"*[37]។ ខ្ញុំចាត់ទុកថា សំណើសុំឱ្យ ខ្ញុំ ស៊ើបអង្កេតលើវិធីសាស្ត្រដែលប្រើប្រាស់ដោយ"ប្រភេទផ្សេងទៀត" គឺមិនជាក់លាក់គ្រប់គ្រាន់អាចឱ្យពិចារណាសំណើនេះឱ្យបានត្រឹមត្រូវឡើយ។

២៧. ទោះបីជាប្រសិនបើ មេធាវីការពារក្តី បានបំពេញតាមលក្ខខណ្ឌភាពជាក់លាក់ក៏ដោយ ក៏ភស្តុតាងតែមួយគត់ដែលបញ្ជាក់ពីការជីកគាស់យកអដ្ឋិធាតុដែលមានការចាត់តាំង គឺការជីកគាស់យកអដ្ឋិធាតុដែលបានធ្វើឡើងនៅឆ្នាំ ១៩៧៩ និង ១៩៨០ ដោយរណសិរ្សសង្គ្រោះជាតិដែលបានជំរុញប្រជាជនឱ្យប្រមូលភស្តុតាងសម្រាប់ការជំនុំជម្រះក្តី ប៉ុល ពត និង អៀង សារី[38]។ ការគាស់យកអដ្ឋិធាតុផ្សេងទៀតបានធ្វើឡើងដោយអ្នកស្រុក ភ្លាមៗបន្ទាប់ពីការដួលរំលំរបបខ្មែរក្រហម ដោយភាគច្រើនដើម្បីស្វែងរកវត្ថុមានតម្លៃ[39]។

២៨. របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ រៀបរាប់ និងវាយតម្លៃអំពីវិធីសាស្ត្រដែលបានប្រើប្រាស់ដោយរណសិរ្សសង្គ្រោះជាតិ[40] ហើយរបាយការណ៍របស់ Graig Etcheson[41] ក៏

---

[37]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[38]របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ ERN00499435។

[39]សំណុំរឿង004 ឯកសារD1.3.11.47 *កំណត់ហេតុនៃការស្តាប់ចម្លើយសេង ស៊្រុន* ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៩។ សំណុំរឿង004 ឯកសារD6.1.381 *កំណត់ហេតុនៃការស្តាប់ចម្លើយសេង ស៊្រុន* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៣។ សំណុំរឿង004 ឯកសារ D1.3.10.5 *របាយការណ៍ស្តីអំពីដំណើរទស្សនៈកិច្ចរបស់ក្រុមគូស ផែនទីគម្រោងស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ទៅកាន់ខេត្តកំពង់ចាម* ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ ទំព័រ ៤។ សំណុំរឿង004 ឯកសារ D1.3.10.23 *របាយការណ៍បេសកកម្ម ក.ស.ព ចុះទៅតំបន់ ៤១ (ប្រតិបត្តិការនៅលើទឹកដីតាមដងទន្លេ)* ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ១៣។ សំណុំរឿង004 ឯកសារD3/20 *កំណត់ហេតុនៃការស្តាប់ចម្លើយស្រី កាន្សឿន* ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០ ឆ.៣។ សំណុំរឿង004 ឯកសារ D107/2 *កំណត់ហេតុនៃការស្តាប់ចម្លើយសាន់ សុន* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.១៤។

[40]របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ ERN00499435, ERN00499436, ERN00499437, ERN00499438 និង ERN00499439។

[41]សំណុំរឿង002 ឯកសារ E3/1807 *ចំនួនដែលបញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា* ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៧-៨ [អង់គ្លេស]។

បានលក្ខណៈដូចគ្នានេះដែរ។ នីតិវិធីទាំងនេះក៏ត្រូវបានរៀបរាប់ដោយសាក្សីមួយចំនួនរបស់ ក.ស.ព និង ក.ស.ច.ស ផងដែរ[42]។

## គ. ភាពពុំត្រឹមត្រូវ វិធីសាស្ត្រខុសឆ្គង និងការវាយតម្លៃភាពអាចជឿជាក់បាន

២៩. តាមដែលមេធាវីការពារក្តី គូសបញ្ជាក់នៅកថាខណ្ឌ ១៣ ដល់ ១៧ នៃសំណើ វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់នៅក្នុងគម្រោងរៀបចំផែនទីរបស់ខ្លួន ត្រូវបានត្រួតពិនិត្យរួចហើយ។ របាយការណ៍អ្នកជំនាញដាច់ដោយឡែកចំនួនពីរ បានពិចារណាលើវិធីសាស្ត្រនេះ ហើយបានវាយតម្លៃភាពអាចជឿជាក់បាននៃវិធីសាស្ត្រនេះ។ វិធីសាស្ត្រនេះក៏បានក្លាយជាកម្មវត្ថុនៃសក្ខីកម្មនៅក្នុងដំណាក់កាលជំនុំជម្រះក្តីសំណុំរឿង ០០២ ដែរ[43]។ បន្ថែមពីលើនេះទៀត សាក្សី ស៊ុន ឃិន បានពន្យល់អំពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បែងចែកឱ្យខុសគ្នារវាងការស្លាប់ដោយសារអំពើហិង្សា និងការស្លាប់តាមធម្មជាតិ ទាក់ទងនឹងការប៉ាន់ស្មានចំនួនជនរងគ្រោះ[44]។ គាត់ក៏បានលម្អិតអំពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់ពេលវេលាដែលជនរងគ្រោះត្រូវបានសម្លាប់[45]។ ខ្ញុំជឿជាក់ថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងគម្រោងរៀបចំផែនទីរបស់ខ្លួន ត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ហើយ ហើយខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវធ្វើការស៊ើបអង្កេតថែមទៀតលើបញ្ហានេះឡើយ។

---

[42] សំណុំរឿង០០៤ ឯកសារ D1.3.11.47 *កំណត់ហេតុនៃកិច្ចសម្ភាសន៍* ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៩។ សំណុំរឿង០០៤ ឯកសារ D3/20 *កំណត់ហេតុនៃការស្តាប់ចម្លើយស្រី កាឡៀន* ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០ ឆ.៤។

[43] សំណុំរឿង០០៤ ឯកសារ D179/1.2.2 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២។ សំណុំរឿង០០៤ ឯកសារ D179/1.2.3 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២។ សំណុំរឿង០០៤ ឯកសារ D179/1.2.4 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២។ សំណុំរឿង០០៤ ឯកសារ D179/1.2.5 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២។

[44] សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ. ១៧។

[45] សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.៨ និង ឆ.១១។

### ឃ. បង្ហាញអត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដូចជា លោក ផេង ពង្សរ៉ាស៊ី

៣០. មេធាវីការពារក្តី បង្ហាញយ៉ាងត្រឹមត្រូវថា ឯកសារស្តាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយនឹង ផេង ពង្សរ៉ាស៊ី មាននៅក្នុងសំណុំរឿង ០០៤ រួចហើយ។ គាត់ត្រូវបានចោទសួរអំពីគម្រោងរៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រាប់បញ្ចូលទាំងភាពមិនស៊ីសង្វាក់គ្នានៅក្នុងទិន្នន័យ[46]។ ដូចបានកត់សម្គាល់ខាងលើ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយអតីតបុគ្គលមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីរនាក់ថែមទៀត គឺ ស៊ិន ឃិន និង ហាក់ សុផល ដែលបានផ្តល់ភស្តុតាងបន្ថែមទៀតទាក់ទងនឹងទិន្នន័យរណ្តៅសាកសពរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[47]។ ហេតុនេះ ខ្ញុំចាត់ទុកថា កិច្ចស៊ើបសួរនេះបានបំពេញចប់សព្វគ្រប់ហើយ។

### ង. ការតែងតាំងអ្នកជំនាញ

៣១. ទោះបីជារបាយការណ៍អ្នកជំនាញប្រជាសាស្ត្រ មិនផ្តោតឱ្យបានជាក់លាក់ទៅលើភូមិភាគកណ្តាល យ៉ាងណាក៏ដោយ ក៏របាយការណ៍នេះ ពិនិត្យបានគ្រប់គ្រាន់អំពីដំណើរការនីតិវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់ និងស្ថាប័នចាត់តាំងផ្សេងទៀត ក្នុងការកំណត់ទិន្នន័យចំនួនជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលកំណត់ហេតុស្តាប់ចម្លើយ ហាក់ សុផល និង ស៊ិន ឃិន បានបង្ហាញដែរ វិធីសាស្ត្ររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគកណ្តាល គឺដូចគ្នានឹងវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នានាដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣។ ហេតុនេះ មិនចាំបាច់តែងតាំងអ្នកជំនាញថ្មីសម្រាប់បញ្ហាដូចគ្នានេះនៅក្នុងសំណុំរឿង ០០៤ ឡើយ។

---

[46]សំណុំរឿង០០៤ ឯកសារ D219/144 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេង ពង្សរ៉ាស៊ី* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥ ឆ.១០-ឆ.១៤។

[47]សំណុំរឿង០០៤ ឯកសារ D219/363 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាក់ សុផល* ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៣២. **ជូនដំណឹង** មេធាវីការពារក្តី ថា ខ្ញុំយល់ឃើញថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងការត្រួតពិនិត្យមើលរណ្តៅសាកសពរួមនៅវត្តអូរត្រកួន វត្តភ្នំប្រុស វត្តអង្គញជី គោកព្រីង និងទួលបេង គឺបានស៊ើបអង្កេតគ្រប់គ្រាន់ហើយ ដូចបានពន្យល់នៅផ្នែកតួសេចក្តីនៃដីកាសម្រេចនេះ។

៣៣. **បដិសេធ** ផ្នែកផ្សេងទៀតទាំងអស់នៃសំណើ។

ភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**